**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2016, 14:48
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

# ពាក្យសុំរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ក្នុងការឆ្លើយតបទៅនឹងឯកសារ E327/4/5

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**
លោកស្រី ទូច វណ្ណរ័ក្ស
លោក Calvin SAUNDERS

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាសូមដាក់សំណើនេះ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងទៅនឹងឯកសារមួយចំនួនដែលបានទទួលយក និងដាក់ក្នុងឃ្លាំងផ្ទុកឯកសាររួមដោយអង្គជំនុំជម្រះសាលាដំបូង[1]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់សំណើសុំ អនុលោមតាមវិធាន៨៧(៤)ពីឯកសារទាំងនេះ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១៦[2]។ អង្គជំនុំជម្រះសាលាដំបូងក៏បានជូនដំណឹងដល់ភាគីផងដែរថា ខ្លួនអាចជ្រើសរើសដើម្បីទទួលយកឯកសារខ្លះ ឬទាំងអស់ តាមយោបល់ផ្ទាល់ខ្លួន[3]។

## II. ប្រវត្តិនីតិវិធី

2. សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះទទួលយកជាភស្តុតាងនូវឯកសារចំនួនប្រាំមួយ ក្នុងចំណោមឯកសារដប់បួនដែលបានទទួលដោយអង្គជំនុំជម្រះសាលាដំបូង។ គ្រប់ឯកសារទាំងអស់ដែលសហព្រះរាជអាជ្ញាបានស្នើឲ្យទទួលយក បំពេញបាននូវលក្ខខណ្ឌស្តីពី "តម្លៃពាក់ព័ន្ធនៃភាពជឿទុកចិត្តបាន យថាភូត និងភាពពាក់ព័ន្ធ ដូចមានចែងក្នុងលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣)"[4]។ ឯកសារទាំងនេះ គួរឲ្យទុកចិត្តបាន និងមានយថាភូត ដោយសារមានទាំងការបកប្រែជាភាសាវៀតណាមនៃសំណៅចម្លងដោយដៃនៃឯកសារសម័យកាលកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើឡើងដោយអ្នកសិក្សាជាន់ខ្ពស់មួយរូប គឺសាស្ត្រាចារ្យ Christopher Goscha ដែលអង្គជំនុំសាលាដំបូងបានធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ ស្តីពីរបៀបដែលគាត់បានទទួលឯកសារទាំងនេះ[5]។ សាស្ត្រាចារ្យ Goscha បានបញ្ជាក់ប្រាប់អង្គជំនុំជម្រះសាលាដំបូងថា ទោះបីគាត់មិនធ្លាប់ឃើញឯកសារដើមជាភាសាខ្មែរក៏ដោយ ក៏គាត់ធ្លាប់ចម្លងដោយដៃនៃឯកសារបកប្រែជាភាសាវៀតណាម ពេលគាត់ធ្វើ

---

[1] **E327/4/5** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពី "ការបកប្រែឯកសារភាសាវៀតណាម ដែលទទួលបានពីបណ្ណសារនៃសាកលវិទ្យាល័យតិចសាស់ ដែលមានប្រភពដើមចេញពីការស្រាវជ្រាវរបស់ Christopher Goscha", ២៤ សីហា ២០១៦ (ចាប់ពីនេះតទៅហៅថា "អនុស្សរណៈ Goscha")។

[2] សារអេឡិចត្រូនិក ពី Matteo Crippa, ២ កញ្ញា ២០១៦។ **E327/4/5** អនុស្សរណៈ Goscha, កថាខណ្ឌ៤។ សេចក្តីព្រាងប្រតិចារិកសវនាការ, ២៥ សីហា ២០១៦, ទំព័រជាភាសាអង់គ្លេស ២៥-២៦។

[3] សេចក្តីព្រាងប្រតិចារិកសវនាការ, ២៥ សីហា ២០១៦, ទំព័រជាភាសាអង់គ្លេស ២៦។

[4] **E424/1** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា តាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសាក្សី 2-TCW-1005, ២ កញ្ញា ២០១៦, គ្រង់កថាខណ្ឌ៤។

[5] **E327/4/5.4** សារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង ជាមួយ Christopher Goscha។

ការស្រាវជ្រាវនៅឯបណ្ណាល័យយោធាប្រជាជននៅក្នុងទីក្រុងហាណូយ[6]។ គាត់មិនមានការសង្ស័យណាមួយឡើយទាក់ទងនឹងយថាភូតរបស់ឯកសារទាំងនេះ ហើយគាត់ឱ្យយោបល់ថា "យោធាត្រូវតែមានឯកសារដើមជាភាសាខ្មែរ"[7]។ គាត់ក៏បានបញ្ជាក់ផងដែរអំពីភាពពេញលេញនៃនៃសំណៅចម្លងទាំងនេះ ដោយមានប្រសាសន៍ថា "ខ្ញុំចាំថា ពេលខ្ញុំកំពុងព្យាយាមកត់ត្រាអ្វីៗគ្រប់យ៉ាងគឺយើងសរសេរត្រង់ៗ"[8]។ អ្នកជំនាញក្នុងសំណុំរឿង០០២ លោក Phillip Short យ៉ាងហោចណាស់ បានពឹងផ្អែកទៅលើឯកសារចំនួនពីរនៃឯកសារ ដែលបានផ្ដល់ឱ្យគាត់ដោយសាស្ត្រាចារ្យ Goscha (រួមបញ្ចូលផងដែរនូវឯកសារដែលទទួលបានដោយអង្គជំនុំជម្រះសាលាដំបូង) ក្នុងការសរសេរសៀវភៅរបស់គាត់ដែលមានចំណងជើងថា "ប៉ុល ពត ប្រវត្តិនៃសុបិនអាក្រក់មួយ"[9] (Pol Pot, The History of a Nightmare) ដែលមាននៅក្នុងសំណុំរឿង[10]។ ការពឹងពាក់របស់អ្នកជំនាញ Short នៅលើឯកសារទាំងនេះ ដែលថាមានយថាភូត គឺជាការបោះជំហានមួយបន្ថែមទៀតចំពោះភាពជឿជាក់បាននៃឯកសារ។ សហព្រះរាជអាជ្ញាកត់សម្គាល់ផងដែរថា ឈ្មោះរបស់អ្នកបកប្រែវៀតណាម ព្រមទាំងកាលបរិច្ឆេទនៃការបកប្រែដែលបានកំណត់អត្តសញ្ញាណសម្រាប់ឯកសារជាច្រើននៃឯកសារដែលទទួលបានដោយអង្គជំនុំជម្រះសាលាដំបូង បង្ហាញឱ្យឃើញអំពីភាពជាប្រព័ន្ធ និងជាអាជីពដែលជាមូលដ្ឋាននៃការបកប្រែ។

3. ភាពជឿជាក់បាននៃខ្លឹមសារនៃឯកសារទាំងនេះ គឺបានបង្ហាញបន្ថែមទៀតតាមរយៈការពិតដែលថាទិដ្ឋភាពនៃព័ត៌មានដែលមាននៅក្នុងឯកសារទាំងនេះ ជាញឹកញាប់ត្រូវបានផ្ទៀងផ្ទាត់ដោយឯកសារដទៃទៀតដែលមាននៅក្នុងសំណុំរឿង។ ជាឧទាហរណ៍ ចំណុចនេះ រួមមានឈ្មោះហៅក្រៅរបស់កម្មាភិបាលខ្មែរក្រហម[11] លេខកូដសម្ងាត់មន្ទីរ (ឧ. "មន្ទីរ ៨៧០"[12]) លេខកូដសម្ងាត់ភូមិសាស្ត្រ (ឧ. "តំបន់ ២១"[13]) គោលនយោបាយនានា (ឧ. "បីតោន ក្នុងមួយហិកតា"[14]) និងបញ្ហាអង្គហេតុនានា[15] ដែលឆ្លុះបញ្ចាំងនៅក្នុងឯកសារសម័យកម្ពុជាប្រជាធិបតេយ្យនៅក្នុងសំណុំរឿង។

---

[6] **E327/4/5** អនុស្សរណៈ Goscha, កថាខណ្ឌ១។

[7] **E327/4/5** អនុស្សរណៈ Goscha, កថាខណ្ឌ១។

[8] **E327/4.5.4** សារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង ជាមួយ Christopher Goscha ត្រង់ទំព័រ១។

[9] See **E327/4.5.3** សារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង ជាមួយ Philip Short, ត្រង់ទំព័រ២។

[10] **E3/9** Philip Short, "ប៉ុល ពត ប្រវត្តិនៃសុបិនអាក្រក់មួយ" ២០០៥។

[11] *សូមមើលជាឧទាហរណ៍* ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313109។

[12] *សូមមើលជាឧទាហរណ៍* ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320887។

[13] *សូមមើលជាឧទាហរណ៍* ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313121។

4. ឯកសារដែលសហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយក គឺជាឯកសារពាក់ព័ន្ធ "ដោយសារជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងបញ្ហាដែលបានជំនុំជម្រះ នៅក្នុងសំណុំរឿង០០២/០២"[16]។ សហព្រះរាជអាជ្ញាពន្យល់បន្ថែមនៅខាងក្រោម ទាក់ទងនឹងភាពពាក់ព័ន្ធនៃឯកសារនិមួយៗ ដោយលើកយោងឯកសារនេះ តាមលេខដែលមាននៅក្នុងបញ្ជីដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូង ត្រង់ E327/4/5.1[17]។

5. **ឯកសារទី១** មានចំណងជើងថា "សម្រង់ពីឯកសារមួយចំនួនពីមន្ទីរ ៨៧០"[18]។ ក្នុងឯកសារទីមួយនេះ មានភស្តុតាងដែលពាក់ព័ន្ធនឹងការកំណត់គោលដៅជនជាតិវៀតណាម សិទ្ធិអំណាចរបស់ នួន ជា មូលហេតុក្នុងការជម្លៀសមនុស្សពីភូមិភាគបូព៌ា មនោគមវិជ្ជារបស់ បកក និងការដឹងឮ និងសិទ្ធិអំណាចរបស់ ខៀវ សំផន ចំពោះបញ្ហាទាំងនេះ តាមរយៈភាពពាក់ព័ន្ធរបស់គាត់នៅមន្ទីរ ៨៧០។

6. ឯកសារនេះកត់សម្គាល់យ៉ាងហោចណាស់កិច្ចប្រជុំមួយ ដែលបានដឹកនាំធ្វើដោយ "បងធំទីពីរ"[19] ហៅ នួន ជា ហើយគាត់បានថ្លែងយ៉ាងមានអំណាចអំពី "មាគ៌ានយោបាយនៅក្នុងបក្សយើង"[20]។ នៅក្នុងកិច្ចប្រជុំដែលដឹកនាំដោយ នួន ជា នេះ មានការរៀបរាប់អំពីមូលហេតុដែលក្រុមប្រជាជនដ៏ធំ ត្រូវបានគេបញ្ជូនចេញពីភូមិភាគបូព៌ា។ វាមិនមែនមកពីសុវត្ថិភាព ឬសុខុមាលភាពរបស់ពួកគេទេ ប៉ុន្តែវាជា "ការសម្រេចដើម្បីដកចេញនូវប្រជាជនចំនួន៦០.០០០នាក់ ដែលកំពុងរស់នៅតាមព្រំដែនគឺ ... ជារឿងត្រឹមត្រូវ ដោយសារថា ប្រសិនបើយើងមិនផ្លាស់ទីលំនៅប្រជាជនទាំងនោះទេ ពួកគេនឹងធ្វើកុបកម្មពីខាងក្នុងជាមិនខាន"[21]។

---

[14] *សូមមើលជាឧទាហរណ៍* ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01323780។

[15] *សូមមើលជាឧទាហរណ៍* កិច្ចពិភាក្សានៃឯកសារទី៨ ខាងក្រោម។

[16] **E319/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទិននឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣ និង០០៤, ២៤ ធ្នូ ២០១៤, កថាខណ្ឌ១០។

[17] **E327/4/5.1** សំណៅចម្លងនៃឯកសារភាសាវៀតណាម ដែលទទួលបានដោយសាស្ត្រាចារ្យ Goscha។

[18] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320887។

[19] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320889។

[20] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320892។

[21] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320889។

7. ទាក់ទងនឹងការកំណត់គោលដៅជនជាតិវៀតណាមនេះ កំណត់ហេតុនៃអង្គប្រជុំនានា កត់សម្គាល់ថា ទិដ្ឋភាពមួយនៃ "គោលការណ៍ណែនាំរបស់[មន្ទីរ]៨៧០" គឺ "ការប្រមូលជនជាតិ និងការស្អប់ខ្ពើមវណ្ណៈនៅក្នុងសហគមន៍ ចំពោះជនឈ្លានពានវៀតណាម និងដើម្បីលើកស្ទួយភាពស្អប់ខ្ពើមចំពោះជនជាតិនេះ ឲ្យក្លាយទៅជាការតម្រង់ទិសជាក់ស្តែងមួយ"[22]។

8. ឯកសារនេះ ក៏ជាភ្លើងបំភ្លឺនៅលើមនោគមវិជ្ជារបស់ បកក ជាទូទៅផងដែរ ដោយកត់សម្គាល់ថា "គោលជំហរវណ្ណៈពលកររបស់បក្ស" រួមបញ្ចូលនូវ "គោលជំហរនៃការលះបង់សិទ្ធិលើកម្មសិទ្ធិជាក់ស្តែង សិទ្ធិទទួលអំណាច បុព្វសិទ្ធិនៃសេរីភាពនៃការគិត"[23]។ ឯកសារនេះ ផ្ទៀងផ្ទាត់អ្វីដែលមានក្នុងកម្មសិទ្ធិជាក់ស្តែងនោះ គឺវណ្ណៈពលករត្រូវតែត្រៀមខ្លួនដើម្បីលះបង់"ជីវិត"[24] និងថាពួកគេត្រូវតែ "គោរពដោយគ្មានលក្ខខណ្ឌ ទាំងក្នុងកាលៈទេសៈងាយស្រួល និងកាលៈទេសៈលំបាក"[25] ផងដែរ។

9. **ឯកសារទី៦** មានចំណងជើងថា "ការសម្រេចរបស់មជ្ឈិមបក្ស ប៉ុល ពត, មិថុនា ១៩៧៦"[26]។ ឯកសារនេះពាក់ព័ន្ធ ដោយសារបង្ហាញពីការផ្តល់ដោយគណៈមជ្ឈិម នូវសេចក្តីណែនាំទាក់ទងនឹងគោលនយោបាយពលកម្មដោយបង្ខំ និងការស្រាវជ្រាវរុករកជនណាដែលមាន "ប្រវត្តិខ្មាំង"។ ទាក់ទងនឹងគោលនយោបាយពលកម្មការងារដោយបង្ខំ គណៈមជ្ឈិមបានប្រកាសឲ្យប្រើលក្ខខណ្ឌតម្រូវ "បីតោនក្នុងមួយហិកតា" និងដើម្បីជួយសម្រួលដល់វិស័យកសិកម្ម គេមានលក្ខខណ្ឌតម្រូវជាច្រើន ដើម្បីកសាងរចនាសម្ព័ន្ធផ្សេងៗ ដើម្បីលើកស្ទួយដល់ប្រព័ន្ធស្រោចស្រព[27]។ ចំពោះបញ្ហាប្រវត្តិខ្មាំងវិញ បង្ហាញអំពីការប្រកាសឲ្យប្រើដោយគណៈកម្មាធិការមជ្ឈិមនូវសេចក្តីណែនាំ ដើម្បី "ស្រាវជ្រាវរកសមាធាតុគ្រោះថ្នាក់ និងបំផ្លិចបំផ្លាញ" ពី "ខាងក្នុងបក្ស និងកងទ័ពបដិវត្ត"[28] និង

---

[22] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320890 (សង្កត់ន័យត្រង់ពាក្យមានគូសបន្ទាត់ពីក្រោម)។

[23] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320893។

[24] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320893។

[25] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01320894។

[26] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01323780-01323781។

[27] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01323781, កថាខណ្ឌ៣។

[28] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01323780-81, កថាខណ្ឌ២។

ការអះអាងថា "គឺជារឿងចាំបាច់ដែលត្រូវធ្វើដើម្បីខំប្រឹងស្រាវជ្រាវរកកម្មាភិបាល និងសមាជិកបក្សនៅក្នុងមហាចលនាកម្មករ កសិករ និងកងទ័ពបដិវត្ត..."[29]។

10. **ឯកសារទី៧** មានចំណងជើងថា "អង្គប្រជុំដើម្បីពិភាក្សាអំពីការងារនៅក្នុងអង្គការអចិន្ត្រៃយ៍របស់ ប៉ុល ពត នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៤"[30] និងនៅលើសៀវភៅមួយក្បាលនៃសកលវិទ្យាល័យបច្ចេកទេសតិចសាស ថា "កិច្ចប្រជុំមួយរបស់មន្ទីរគណៈអចិន្ត្រៃយ៍របស់ ប៉ុល ពត ចាត់តាំងការងារនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៧៦"[31]។ សហព្រះរាជអាជ្ញាកត់សម្គាល់ចំពោះភាពខុសគ្នារវាងឯកសារបកប្រែជាភាសាអង់គ្លេស និងកាលបរិច្ឆេទដែលបានផ្តល់នៅក្នុងសៀវភៅមួយក្បាលនោះ។ ដោយពិនិត្យទៅលើឯកសារដើមជាភាសាវៀតណាម[32] ហាក់ដូចជាថា ឆ្នាំ១៩៧៦ ដូចបានឆ្លុះបញ្ចាំងលើសៀវភៅមួយក្បាលនោះ គឺត្រឹមត្រូវ។ ទោះបីការសរសេរដោយដៃចំពោះលេខ "៦" នៅខាងលើនៃឯកសារនេះមានទម្រង់ផ្ដុំឡើងដូចលេខ "៤" ក្តី តែការប្រៀបធៀបទៅនឹងលេខ "៤" ផ្សេងទៀតរបស់សាស្ត្រាចារ្យ Goscha នៅលើឯកសារនេះបង្ហាញថា វាមិនស្រដៀងគ្នាទេ។ លើសពីនេះ ឯកសារពិភាក្សាតែលើបញ្ហាណាដែលអាចកើតឡើងបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប៉ុណ្ណោះ។ និយាយឲ្យចំ ឯកសារកត់សម្គាល់ថា អៀង ធីរិទ្ធ *ហៅ* ភា "ទទួលខុសត្រូវចំពោះសុខភាពសាធារណៈនៅភ្នំពេញ និងរោងចក្រឱសថនៅភ្នំពេញ"[33]។

11. កំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍មួយឈុតនេះ ហាក់ដូចជាមិនទាន់មាននៅលើសំណុំរឿងនៅឡើយ ហើយពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃសិទ្ធិអំណាចនៅក្នុង បកក ដោយសារផ្តល់នូវការទទួលខុសត្រូវរបស់មេដឹកនាំ បកក ដោយឡែកៗពីគ្នា។ និយាយចំពោះ នួន ជា គឺឆ្លុះបញ្ចាំងពីអំណាចរបស់គាត់ថាជា "អនុ, ការទទួលខុសត្រូវរួម" ព្រមទាំងការទទួលខុសត្រូវរបស់គាត់លើការងារ "ឃោសនាអប់រំនយោបាយ និងមនោគមវិជ្ជា"[34]។ ឯកសារក៏មានការកត់សម្គាល់ផងដែរថា ឈឹម សំអោក *ហៅ* ប៉ុង គឺជា "អ្នកក្រោមបង្គាប់ផ្ទាល់របស់សមមិត្ត នួន"[35]។

---

[29] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01323781, កថាខណ្ឌ៥(ក)។

[30] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 0131309។

[31] **E327/4/5.2** សៀវភៅ: ឯកសារខ្មែរក្រហម, ENG 01321234។

[32] ឃ្លាំងផ្ទុកឯកសាររួម SMD VN 01241117។

[33] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313110។

[34] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313109។

[35] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313110។

12. **ឯកសារទី៨** មានចំណងជើងថា “អង្គប្រជុំគណៈអចិន្ត្រៃយ៍របស់ ប៉ុល ពត ពិភាក្សាអំពីសភាជាតិ, ៣០ មីនា ១៩៧៦”[36]។ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍មួយឈុតនេះ ហាក់ដូចជាមិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយ ហើយសហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារនេះគួរបានដាក់បញ្ចូល អាស្រ័យដោយមូលហេតុនៃសារៈសំខាន់ទូទៅរបស់កំណត់ហេតុនៃអង្គប្រជុំទាំងនោះ។ ជាការបន្ថែម ឯកសារនេះក៏ជាប់ទាក់ទងនឹងភស្តុតាងផ្សេងទៀត ដែលមាននៅលើសំណុំរឿងផងដែរ។ ឧទាហរណ៍ ឯកសារនេះ ពិភាក្សាពី“បញ្ហានៃការប្រើប្រាស់សីហនុ” និងបំណងរបស់សម្តេចសីហនុ ក្នុងការលាលែង”[37]។ បញ្ហានេះ ក្រោយមក ក៏ត្រូវបានលើកយកមកពិភាក្សាគ្នាក្នុងរបៀបផ្សេង និងមានលក្ខណៈជាការឃោសនាច្រើនជាង នៅក្នុងរបាយការណ៍ដែលពាក់ព័ន្ធនឹងសភាតំណាងប្រជាជនកម្ពុជា ដែលបានធ្វើឡើងនៅថ្ងៃទី១១-១៣ ខែមេសា ឆ្នាំ១៩៧៦”[38]។ ខៀវ សំផន ក៏បានរាយការណ៍អំពីការលាលែងរបស់សម្តេចសីហនុ និងវាសនារបស់ព្រះអង្គនៅក្នុងកំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍មួយឈុតផ្សេងទៀត ដែលមាននៅក្នុងសំណុំរឿង[39]។ ឯកសារទី៨នេះ ក៏មានការកត់សម្គាល់ចំពោះការតែងតាំង ខៀវ សំផន ជាប្រធាននៃគណៈប្រធានរដ្ឋផងដែរ[40] ដែលជាការតែងតាំងមួយ ដែលបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ដែលពាក់ព័ន្ធទៅនឹងសភាតំណាងប្រជាជនកម្ពុជា[41]។

13. **ឯកសារទី១១** គឺជាកម្រងនៃកំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលមានចំណងជើងថា “សម្ភារៈនៃកំណត់ហេតុនៃអង្គប្រជុំរបស់ ប៉ុល ពត”[42]។ ឯកសារនេះ គឺពាក់ព័ន្ធដោយសារបង្ហាញពីការដឹងឮ ការអនុម័ត និងការគ្រប់គ្រងលើការបោសសម្អាតនៅក្នុងកម្ពុជាប្រជាធិបតេយ្យរបស់គណៈអចិន្ត្រៃយ៍ ព្រមទាំងដំណើរការនៃការស្រាវជ្រាវរុករក ដែលជួយសម្រួលដល់ការបោស

---

[36] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313105។

[37] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313105។

[38] *សូមមើលជាឧទាហរណ៍* **E3/165** ឯកសារស្តីពីសន្និបាតលើកទី១ សម័យកាលទី ១ របស់សភាតំណាងប្រជាជនកម្ពុជា ១១-១៣ មេសា ៧៦, ENG 00184067។

[39] **E3/197** កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍, ១១ មិនា ១៩៧៦។

[40] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313106។

[41] **E3/165** ឯកសារស្តីពីសន្និបាតលើកទី១ សម័យកាលទី ១ របស់សភាតំណាងប្រជាជនកម្ពុជា ១១-១៣ មេសា ៧៦, ENG 00184068។

[42] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01324075។

សម្អាតទាំងនោះ។ ជាឧទាហរណ៍ កំណត់ហេតុនៃអង្គប្រជុំចុះថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៧ មាន បញ្ចូលកថាខណ្ឌដូចខាងក្រោម៖

- **ខ្មាំងខាងក្នុង:** ក្នុងឆ្នាំ១៩៧៦ យើងបានកម្ទេចពួកប្រតិកិរិយាជាច្រើន ដែលមកពីអង្គការសំខាន់ៗ រួមទាំងពួកសេរី និងពួកស៊ីអាយអេ។ ប៉ុន្តែ យើងនៅតែត្រូវការរុករកពួកគេថែមទៀត ដោយសារពួកគេនៅតែមានការលាក់ខ្លួននៅក្នុងជួររបស់យើង”[43]។

- “**ការអភិវឌ្ឍន៍អង្គការ:** ត្រូវមានវិធានការដោយប្រសិទ្ធភាព ដើម្បីអប់រំ និងបោសសម្អាតពួកប្រតិកិរិយានៅក្នុងជួរយោធារបស់យើង។ ជាពិសេស ត្រូវស្នើឲ្យទាហានដាក់ប្រវត្តិរូបរបស់ខ្លួន ហើយយើងត្រូវតែមានផែនការដើម្បីតាមដានទាហានដែលសង្ស័យ។ ផែនការរបស់យើង គឺថានៅត្រឹមពាក់កណ្តាលឆ្នាំ១៩៧៧ យើងត្រូវតែមានប្រវត្តិរូបរបស់មន្ត្រីជាន់ខ្ពស់កងវរសេនាធំ កងវរសេនាតូច និងកងអនុសេនាធំទាំងអស់ ហើយមានប្រវត្តិរូបរបស់ទាហាន (ប្រុស ស្រី) ទាំងអស់នៅត្រឹមបំណាច់ឆ្នាំ១៩៧៧”[44]។

- “**ការងារបង្កើត ពង្រឹង និងអភិវឌ្ឍន៍សមាជិកបក្ស:** ការពង្រឹងការអនុវត្តជាមូលដ្ឋាននៃសមាជិកបក្ស ដោយសារបេសកកម្មបោសសម្អាតនៅតាមបណ្តាអង្គភាពនានារបស់យើងអនុវត្តមិនបានល្អ ហើយមិនបានបន្សល់ទុកឲ្យយើងនូវភាពស្អាតស្អំទាំងស្រុងទេ។ ដូច្នេះ ឃើញមានការកើនឡើងនៃសមាជិកបក្ស ដែលយើងមិនអាចធានាបានចំពោះគុណសម្បត្តិខាងសីលធម៌ និងនយោបាយរបស់ពួកគេ។ យ៉ាងណាមិញ ការពង្រីកបេសកកម្មរបស់សមាជិកបក្ស គួរត្រូវធ្វើបន្ត ប្រសិនបើមានអង្គភាពណាមួយបានអនុវត្តបេសកកម្មបោសសម្អាតបានល្អ និងអាចយកប្រវត្តិរូបទាហានរបស់ពួកគេ”[45]។

14. **នៅផ្នែកផ្សេងទៀតនៃឯកសារនេះ កំណត់ហេតុនៃអង្គប្រជុំថ្ងៃទី១៣ មេសា ១៩៧៧ មានបញ្ចូល** ចំណារ “ការបន្តវាយប្រយុទ្ធប្រឆាំងនឹងពួកប្រតិកិរិយាខាងក្នុង និងមូលដ្ឋានរបស់យើង ដើម្បីលើកកម្ពស់ និងពន្លឿនបេសកកម្មក្នុងឆ្នាំ១៩៧៧”[46]។ កំណត់ហេតុនៃអង្គប្រជុំមួយឈុតផ្សេងទៀតមានបញ្ចូលអាជ្ញាបញ្ញាដូចតទៅនេះ ៖ “ដាក់ការងារនៅក្នុងគណៈអចិន្ត្រៃយ៍: ផ្អែកលើសេចក្តីសម្រេច

---

[43] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01324076, កថាខណ្ឌ៣។

[44] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01324077, កថាខណ្ឌ២។

[45] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01324077។

[46] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01324080។

របស់មជ្ឈិមបក្ស និងគណៈអចិន្ត្រៃយ៍ៈ សេចក្តីណែនាំទាក់ទងនឹងការអនុវត្ត គឺការបន្តស្រាវជ្រាវតាមប្រមាញ់ខ្មាំង"[47]។

15. **ឯកសារទី១៣** មានចំណងជើងថា "របាយការណ៍នៅសន្និបាតពាក់កណ្តាលឆ្នាំ១៩៧៧ របស់ភូមិភាគបូព៌ា (ចាប់ពីថ្ងៃទី១៧ ខែកក្កដា ១៩៧៧)"[48] និងជាឯកសារចុងក្រោយដែលសហព្រះរាជអាជ្ញាដាក់ជូនសុំឱ្យទទួលយក។ ឯកសារនេះមានផ្ទុកនូវភ័ស្តុតាងដែលពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង ជម្លោះប្រដាប់អាវុធជាមួយវៀតណាម ការកំណត់គោលដៅជនជាតិវៀតណាម និងគោលនយោបាយពលកម្មដោយបង្ខំ។

16. ទាក់ទងនឹងជម្លោះប្រដាប់អាវុធជាមួយវៀតណាម របាយការណ៍បញ្ជាក់ថា រឿងនឹងមកដល់មួយនៃ "រឿងនឹងមកដល់ជាច្រើន" ដែលពួកគេត្រូវតែ "ខំប្រឹងជន្នះ" គឺ "គំនិតសន្តិនិយម"[49] បង្ហាញឱ្យឃើញថា ដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះប្រដាប់អាវុធជាមួយវៀតណាម គឺជាការប្រទេចផ្តាសាចំពោះមនោគមវិជ្ជារបស់ខ្មែរក្រហម។

17. ទាក់ទងនឹងគោលនយោបាយពលកម្មដោយបង្ខំវិញ ឯកសារនេះអះអាងថា "សេចក្តីណែនាំអំពីគោលនយោបាយរបស់យើង គឺដើម្បីកសាងកសិកម្មទំនើបឱ្យបានឆាប់រហ័សបំផុត"[50]។

18. ឯកសារនេះមានភស្តុតាងជាច្រើនពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង និងអំពីការផ្តោតគោលដៅទៅលើពួកវៀតណាម ឬបុគ្គលដែលបានគិតថាជាវៀតណាម។ ឯកសារនេះទាក់ទងនឹង "យើងបានបំផ្លាញខ្មាំងពីខាងក្រៅ និងបានបំផ្លាញបណ្តាញបង្កប់នៅខាងក្នុង។ ក្រុមខ្មាំងដែលមានទំនាក់ទំនងសម្ងាត់ និងជាកញ្ជះយួនដែលនៅក្នុងបក្សតាំងពីឆ្នាំ១៩៤៨ ឥឡូវនេះ ត្រូវបានកម្ចាត់ចោល ហើយយើងមានលទ្ធភាពបំផ្លាញពួកវាចោលជាមូលដ្ឋាន ដោយឡែក នៅតំបន់២១"[51]។ វាបានអះអាងសូម្បីតែ "ក្នុងអំឡុងពេលប្រាំមួយខែ យើងបានកម្ទេចពួកខ្មាំងអស់ជាច្រើនរយនាក់" និង "យើងបានតាមដាន និងបោសសម្អាតពួកខ្មាំង"[52]។ សត្រូវនេះមានពួក "ក្រុមខាងក្នុង"[53], "ក្រុម

[47] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01324081។

[48] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313118។

[49] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313118។

[50] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313118។

[51] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313120-21។

[52] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313121។

ក្បត់ពួកឆ្កែ រួមមាន ពួកចក្រពត្តិឆ្កែសេអ៊ីអា" និង "ពួកប្រតិកិរិយាខាងក្នុង" ដែលជាពួក "ជាក់ស្តែង ជាពួកមេដឹកនាំ"[54]។ របាយការណ៍បានបន្តដោយសេចក្តីពិស្តារថា៖

> ជាមួយគ្នានោះ ពួកប្រតិកិរិយានៅក្នុងជួរយើង កងកម្លាំងដែលពួកយួនពឹងផ្អែក ត្រូវបានកម្ទេចជាបន្តបន្ទាប់ និងបោសសម្អាតទាំងស្រុងចេញពីតំបន់២៤ ទៅកាន់តំបន់២៣, ២០ និង២១។ ពួកប្រតិកិរិយាទាំងនេះបានបាត់បង់មេដឹកនាំសំខាន់ៗរបស់ពួកគេទាំងអស់ ហើយការបរាជ័យរបស់ពួកខ្មាំង ដោយការកម្ទេចខ្មាំងផ្ទៃក្នុង (ទោះជានៅសល់តិចតួចក៏ដោយ) ហើយសូម្បីតែខ្មាំងខាងក្រៅ ជាពួកយួន ក៏បាត់បង់នូវគ្រឹះទាំងស្រុង, មូលដ្ឋាន និងអង្គការចាត់តាំងទាំងស្រុង ដែលពួកវាត្រូវការចាំបាច់ដើម្បីលេបជាតិសាសន៍របស់យើង។
>
> នៅប្រាំមួយខែដំបូង យើងបានវាយប្រហារពួកខ្មាំងតាមផ្លូវ និងកម្ទេចពួកវាចោលនូវរាល់ចំណុចខ្សោយ និងខ្លាំងរបស់ពួកវា។ ចំណុចខ្លាំងរបស់ពួកខ្មាំងគឺអ្វី? ពួកវាលូនយ៉ាងជ្រៅទៅក្នុងជួរ ប៉ុន្តែពួកដែលកាន់អំណាច ត្រូវបានបោសសម្អាត។ យើងមិនពិបាកទេក្នុងការតាមប្រមាញ់ពួកវាចោល ប៉ុន្តែ ដោយពួកខ្មាំងមាននៅក្នុងជួរដឹកនាំ ទើបពួកវា ពិបាករក។ ពួកវានៅក្នុងជួរដឹកនាំទាំងអស់។ ពួកវាមានបណ្តាញ និងធនធាន និងការទាក់ទងបើកផ្លូវឲ្យយួនចូលមកធ្វើប្រតិបត្តិការជាបន្តបន្ទាប់នៅក្នុងប្រទេសយើង។ ប៉ុន្តែ យើងបានកម្ទេចពួកវា ហើយបានបោសសម្អាតពួកវា ជាប្រព័ន្ធនៅក្នុងទម្រង់មួយធំ ក្នុងអំឡុងពេលប្រាំមួយខែកន្លងមកនេះ[55]។

19. នៅក្នុងតក្កវិជ្ជាបត់បែនរបស់ខ្មែរក្រហម គឺការបោសសម្អាតនេះហើយដែលបានផ្តល់ពួកវានូវកម្លាំង និង "ជ័យជំនះ" ដោយខ្លួនឯង៖

> ដោយសារចម្បាំងវណ្ណៈក្នុងចំណោមប្រជាជនបានកើតឡើងយ៉ាងខ្លាំង ដោយសារកម្លាំងសមូហភាពខ្លាំង និងត្រូវបានដោះស្រាយ សកម្មភាពរបស់ពួកខ្មាំងក្នុងការបង្កប់អ្នកស៊ើបការណ៍ និងពួកប្រតិបដិវត្តត្រូវបានលាតត្រដាង ហើយតាមរយៈនោះ យើងបានបោសសម្អាតពួកវាជាបន្តបន្ទាប់។ តែប្រាំមួយខែដំបូងប៉ុណ្ណោះ យើងបានបោសសម្អាតពួកវា រាប់

[53] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313121។

[54] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313121។

[55] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313124 (សង្កត់ន័យបន្ថែមដោយ គូសបន្ទាត់ពីក្រោម)។

> រយនាក់ ជាឧទាហរណ៍ នៅក្នុងស្រុកឆ្លូង ស្រុកក្រូចឆ្មារ ស្រុកពាមជីលាំង ស្រុកត្បូងឃ្មុំ អង្គភាពទ័ពក្នុងតំបន់២១ ។ល។... ពួកមេបញ្ជាការដឹកនាំរបស់ពួកវានៅតាមមូលដ្ឋាន ត្រូវបានបោសសម្អាតជាមូលដ្ឋាន ដោយសារពួកយើង។ ដោយសារតែរឿងនេះ សូម្បីតែបក្សរបស់យើង មានមនុស្សកាន់តែតិចទៅ ប៉ុន្តែរឹងដូចដែក។ មនុស្សកាន់តែតិច ប៉ុន្តែផ្ទៃក្នុងយើងខ្លាំង។
>
> យើងបានដឹងថា ពួកខ្មាំងលែងមានកន្លែងលាក់ខ្លួនទៀតហើយ។ ជាមូលដ្ឋាន ពួកខ្មាំងបានបាត់មេដឹកនាំរបស់វា។ យើងបានឃើញជ័យជំនះរបស់យើងក្នុងការបំផ្លាញពួកខ្មាំងទាំងខាងក្នុង និងទាំងខាងក្រៅ នៅក្នុងរយៈពេលប្រាំមួយខែដំបូង ក្នុងឆ្នាំ១៩៧៧។ រឿងនេះគេអាចមើលឃើញថា ជាមហាជ័យជំនះប្រវត្តិសាស្ត្រ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា[56]។

20. ឯកសារនេះបង្ហាញថាការបោសសម្អាតនេះ "បង្ហាញថាបក្សយើងមានគោលជំហរដាច់ខាត ក្នុងការវាយប្រហារខ្មាំង"[57] និងបានថ្លែងថាផ្នែកនោះនៃហេតុផលដែលគេអាច "កម្ទេចខ្មាំង បានយ៉ាងល្អប្រសើរ" គឺថាពួកគេអង់អាចនៅក្នុងការ "បំផ្លាញពួកខ្មាំងទាំងអស់ ដោយមិនស្រពិចស្រពិល ដោយមិនស្ទាក់ស្ទើរ"[58] ហើយថាពួកគេបានបន្ត "បោសសម្អាតពួកខ្មាំងដោយមិនឈប់ឈរ"[59]។ ការណ៍នេះបញ្ជាក់ថាចម្ងល់ណាក៏ដោយ ការស្ទាក់ស្ទើរណាក៏ដោយ នៅក្នុងការចោទប្រកាន់បុគ្គលណាក៏ដោយថាជាខ្មាំង និង/ឬនៅក្នុងការសម្លាប់អ្នកដែលបានចោទថាជាខ្មាំង គឺត្រូវបានមើលឃើញថាជាប្រតិបដិវត្ត។

21. សូម្បីតែច្បាស់ជាងនេះ ពាក់ព័ន្ធនឹងការផ្តោតគោលដៅទៅលើពួកវៀតណាម នៅក្នុងភូមិភាគបូព៌ា ឯកសារនេះបានរៀបរាប់អំពីការចាំបាច់បង្កើតនូវ "ការឃោសនា និងការអប់រំប្រជាជន ឲ្យលុបបំបាត់ចោលជាដាច់ខាតនូវឥទ្ធិពលរបស់វៀតណាមក្នុងចំណោមប្រជាជន" រួមមាន "មនុស្សមួយចំនួននៅតាមព្រំដែនដែលបានធ្វើការជាមួយ ឬដែលបានស្គាល់យួន និងដែលមានមនោសញ្ចេតនាជាមួយនឹងយួននៅឡើយ ហើយដែលមិនទាន់អាចត្រូវបានផ្លាស់ប្តូរបាន"[60]។

---

[56] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313125 (សង្កត់ន័យបន្ថែមដោយ គូសបន្ទាត់ពីក្រោម)។

[57] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313121។

[58] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313124។

[59] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313125។

[60] ឃ្លាំងផ្ទុកឯកសាររួម SMD ENG 01313122។

22. អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ឯកសារទាំងអស់នេះត្រូវតាមបមាណីយ *មួយក្រឡេកភ្នែក* នៃវិធាន៨៧(៣)។ សម្រាប់ឯកសារដែលត្រូវតាមបមាណីយទាំងនេះ អង្គជំនុំជម្រះ "អាចទទួលយកជាភស្តុតាងថ្មី ដែលអង្គជំនុំជម្រះចាត់ទុកថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"[61] អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង បានចែងថាភាគីដែលស្នើសុំដាក់ភស្តុតាងថ្មី ត្រូវធ្វើឱ្យអង្គជំនុំជម្រះយល់ថា ភស្តុតាងដែលបានស្នើសុំនោះ គឺមិនអាចរកបានទេ នៅមុនពេលបើកសវនាការ ឬក៏ថាភស្តុតាងនោះ មិនអាចត្រូវបានស្រាវជ្រាវរកឃើញទេ ទោះបីជាមានការអនុវត្តនូវការព្យាយាមសមហេតុសមផលក៏ដោយ[62]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចចំពោះសំណុំរឿង០០២/០២ ថា ការបើកសវនាការនេះកើតឡើងនៅខែមិថុនា ឆ្នាំ២០១១[63]។ ឯកសារទាំងអស់នេះ គឺអាចរកបាននៅមុនការចាប់ផ្តើមសវនាការនេះ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋាន ថាខ្លួនមិនអាចស្រាវជ្រាវរកឃើញទេ ទោះបីជាមានការអនុវត្តនូវការព្យាយាមសមហេតុសមផលក៏ដោយ។ ការណ៍នេះត្រូវបានបង្ហាញដោយអង្គហេតុពិតដែលថា វាបានតម្រូវឱ្យមានអ៊ីមែលជាច្រើនពីអង្គជំនុំជម្រះសាលាដំបូង និងពី WESU ក្នុងគោលបំណងសិក្សាអំពីអត្ថិភាពនៃឯកសារទាំងនេះ ដែលថាឯកសារនោះត្រូវបានរកឃើញនៅឯសាកលវិទ្យាល័យ Texas Tech និងកាលៈទេសៈនានា ដែលនៅក្រោមកាលៈទេសៈទាំងនោះ ឯកសារនោះត្រូវបានបង្កើតឡើង[64]។ សូម្បីតែសហព្រះរាជអាជ្ញាបានដឹងពីសម្ភារៈទាំងនេះ និងទីកន្លែងរបស់វា ឯកសារនោះអាចរកបានតែជាភាសាវៀតណាមប៉ុណ្ណោះ - ដែលជាភាសាមួយដែលសហព្រះរាជអាជ្ញាមិនមានសមត្ថភាពអានបានទេ - ហើយដូច្នេះ សហព្រះរាជអាជ្ញាមិនមានលទ្ធភាពធ្វើការវាយតម្លៃលើបានទេ សម្រាប់ឱ្យទទួលយក។

---

[61] **E319/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទិននឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣ និង០០៤, ២៤ ធ្នូ ២០១៤, កថាខណ្ឌ៩។

[62] **E424/1** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា តាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសាក្សី 2-TCW-1005, ២ កញ្ញា ២០១៦, កថាខណ្ឌ៤។

[63] **E307/1** សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3), ១១ មិថុនា ២០១៤។ **E307/1/2** សេចក្តីសម្រេចលើសំណើសុំរួមឱ្យសម្រេច*សាជាថ្មី* លើការអនុវត្តវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង, ២១ តុលា ២០១៤, កថាខណ្ឌ១០។

[64] *សូមអាន* **E327/4/5.4** អ៊ីមែលរបស់អង្គជំនុំជម្រះសាលាដំបូង ជាមួយនឹង Christopher Goscha។ **E327/4/5** អនុស្សរណៈរបស់ Goscha ។

23. យ៉ាងណាក៏ដោយ ដោយមិនគិតថាតើឯកសារនេះអាចត្រូវបានរកឃើញ ដោយការអនុវត្តនូវ ការព្យាយាមសមហេតុសមផលនៅមុនការចាប់ផ្តើមសវនាការក៏ដោយ ក៏អង្គជំនុំជម្រះនេះបាន "ទទួលយកភស្តុតាងដែលមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យនេះ ដោយរួមទាំងករណីដែលភស្តុតាងទាក់ទងជិតស្និទ្ធជាមួយសម្ភារៈដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើការវាយតម្លៃរួមគ្នាទៅលើប្រភព..."[65]។ ដោយសារតែភាពពាក់ព័ន្ធនៃឯកសារទាំងនេះទៅនឹងសម្ភារៈដទៃទៀតនៅក្នុងសំណុំរឿង ដូចដែលបានរៀបរាប់នៅខាងលើ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ប្រយោជន៍យុត្តិធម៌បានតម្រូវថា ឯកសារនោះគួរត្រូវបានវាយតម្លៃជាមួយគ្នានឹងសម្ភារៈទាំងអស់នៅក្នុងសំណុំរឿង។

## II. **ដំណោះស្រាយដែលស្នើឡើង**

24. សហព្រះរាជអាជ្ញា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកជាភ័ស្តុតាង នូវឯកសារប្រាំមួយដូចបានកំណត់អត្តសញ្ញាណខាងលើ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[65] **E424/1** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា តាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសាក្សី 2-TCW-1005, ២ កញ្ញា ២០១៦, កថាខណ្ឌ៤។